សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រះពុទ្ធជាសង្គមវិទូ

www.hoksavann,com
ថ្ងៃទី១ តុលា ២០១០



បន្ទាប់ពីព្រះពុទ្ធត្រាស់ដឹង មុននឹងយាងទៅសំដែងធម៌ ព្រះអង្គពិចារណានូវបុគ្គលបីពួក ដែលគួរឲ្យព្រះអង្គសំដែងធម៌មុនគេ ព្រោះថាបុគ្គលបីពួកដែលព្រះអង្គបំរុងទៅប្រោសនេះ បើគ្មានធម៌ក្នុងខ្លួនទេ នឹងនាំឲ្យមានគ្រោះថ្នាក់ដល់សង្គម ។ បុគ្គលបីនោះ គឺពួកបញ្ញវ័ន្ត អ្នកមានចំណេះដឹង, ពួកឥស្សរជន អ្នកមានអំណាចបុណ្យស័ក្តិ និងពួកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។

តាមរយៈពុទ្ធប្រវត្តិ ព្រះអង្គបានយាងទៅសំដែងធម៌ទេសនាប្រោសភិក្ខុ៥ព្រះអង្គ ព្រោះភិក្ខុ៥អង្គនោះ ជាក្រុមបញ្ញវ័ន្ត អ្នកស្វែងរកការពិតនៃជីវិតដើម្បីរំដោះទុក្ខ ដែលបួសជាតាបសឥសីតាមបំរើព្រះអង្គ ។ ព្រះអង្គសំដែងអំពីជីវិតសន្តិភាព តាមដំណើរការប្រតិបត្តិមជ្ឈិមា បដិបទា ផ្លូវកណ្តាល ដោយចាត់ទុកនូវផ្លូវអមខាង គឺចិត្តត្រេកត្រអាលនឹងកាមគុណ៥ និងការប្រតិបត្តិធ្វើបាបកាយ ។ ផ្លូវកណ្តាលនោះគឺ មគ្គប្រកបដោយអង្គប្រាំបី រួមឲ្យខ្លីបានដល់សីលសមាធិនិងបញ្ញា ។ ភិក្ខុ៥អង្គនោះបានសំរេចធម៌ជាន់ខ្ពស់ រួចស្រឡះចាកអាសវក្កិលេស សេចក្តីទុក្ខគ្រប់យ៉ាងមានជាតិទុក្ខជាដើម បានត្រូវរំដោះហើយ ។ ភិក្ខុ៥អង្គជាសាវក បានជាសហការីជំនួយព្រះអង្គក្នុងការសំដែងធម៌ទេសនាប្រោសសត្វជាបន្តទៅទៀត ។ បើព្រះអង្គ ពុំបានសំដែងធម៌ប្រោសភិក្ខុ៥អង្គឲ្យយល់មាគ៌ាពិតឆ្ពោះទៅរកការរំដោះទុក្ខទេ តាបសទាំង៥អង្គដែលមហាជនសម័យនោះគោរពបូជា នឹងដឹកនាំមហាជនឲ្យប្រតិបត្តិតាមមាគ៌ារបស់លោក ដែលពុំមែនជាផ្លូវរំដោះទុក្ខ និងនាំឲ្យសង្គមវង្វេងផ្លូវនិងបែកបាក់គ្នា ។

បន្ទាប់មកព្រះពុទ្ធយាងទៅប្រោសព្រះបាទពិម្ពិសារ ព្រះបាទបសេនទិកោសល ជាព្រះមហាក្សត្រគ្រប់គ្រងអំណាចនាសម័យនោះ មួយអន្លើដោយរាជអាមាត្យ ដែលស្មើនឹងរដ្ឋមន្ត្រីបច្ចុប្បន្ននេះ ឲ្យអនុវត្តតាមគន្លងធម៌ ជាពិសេសឲ្យមានទសពិធរាជធម៌ ដែលជាធម៌របស់អ្នកគ្រប់គ្រងអំណាច ។ បើអ្នកគ្រប់គ្រងអំណាចគោរពតាមធម៌របស់អ្នកដឹកនាំ នឹងធ្វើឲ្យប្រទេសបានសុខសន្តិភាព និងលូតលាស់ចំរើន ហើយប្រជាពលរដ្ឋនឹងរួមសាមគ្គីគ្នាយ៉ាងរឹងមាំ ដែលបរទេសពុំអាចចូលមកឈ្លានពានបាន ។ ផ្ទុយទៅវិញបើអ្នកដឹកនាំគ្មានធម៌ក្នុងខ្លួន និងជិះជាន់សង្កត់សង្កិនរំលោភសិទ្ធិប្រជាពលរដ្ឋ ធ្វើឲ្យប្រជាពលរដ្ឋរងទុក្ខវេទនា នោះនឹងធ្វើឲ្យប្រទេសគ្មានសុខសន្តិភាពឡើយ ។ សម័យនោះ ព្រះមហាក្សត្រទាំងឡាយមានព្រះបាទពិម្ពិសារជាដើម បានដើរតាមព្រះធម៌នៃព្រះពុទ្ធជាម្ចាស់ ធ្វើឲ្យប្រទេសបានសុខសន្តិភាព ហើយបានថ្វាយខ្លួនជាញោមឧបដ្ឋាកទំនុបបំរុងព្រះពុទ្ធសាសនាឲ្យលូតលាស់សំរើនថែមទៀត ។ មានព្រះមហាក្សត្រខ្លះ ដោយគោរពនិងជឿស៊ប់ក្នុងព្រះពុទ្ធ ពេលមានកិច្ចការសំខាន់ក្នុងរដ្ឋ បានទៅថ្វាយបង្គំព្រះពុទ្ធដំណាលទូលព្រះអង្គឲ្យបានជ្រាប ដោយចង់ដឹងថា បើមានកិច្ចការណាពុំល្អ ពិតជាព្រះពុទ្ធមានព្រះពុទ្ធដីកាពុំខានឡើយ ។

បន្ទាប់មកទៀត ព្រះពុទ្ធយាងទៅសំដែងធម៌ទេសនាប្រោសសេដ្ឋី គហបតី អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដូចជាអនាថបិណ្ឌិកសេដ្ឋី នាងវិសាខាជាដើម ឲ្យជនទាំងឡាយនោះលុះក្នុងធម៌ កុំឲ្យទ្រព្យសម្បត្តិជាមធ្យោបាយជិះជាន់អ្នកក្រីក្រ តែត្រូវយកទ្រព្យសម្បត្តិទាំងនោះ បូជាសមណព្រាហ្មណ៍អ្នកមានសីល និងធ្វើសង្គហទានដល់អ្នកក្រីក្រលំបាក ។ អនាថបិណ្ឌិកសេដ្ឋី, នាងវិសាខា មានឈ្មោះក្នុងគម្ពីរព្រះពុទ្ធសាសនាថា បានកសាងវត្តអារាម មានវត្តជេតពនជាដើម ថ្វាយចំពោះព្រះពុទ្ធជាម្ចាស់ ហើយបានជួយសង្គ្រោះដក់អ្នកក្រីក្រអនាថាគ្មានទីពឹង ស្របនឹងឈ្មោះរបស់សេដ្ឋីថា អនាថបិណ្ឌិកសេដ្ឋី ប្រែថា សេដ្ឋីអ្នកជួយសង្គ្រោះដល់អ្នកអនាថា ។

ដូច្នេះឃើញថា ព្រះធម៌របស់ព្រះពុទ្ធ ពុំមែនជាធម៌ក្រៅសង្គមឡើយ គឺជាធម៌សំរាប់សង្គមមនុស្សគ្រប់ជាន់ថ្នាក់ ទាំងអ្នកកាន់អំណាច ទាំងប្រជាពលរដ្ឋប្រតិបត្តិតាម ជាពិសេសព្រះអង្គសំដែងធម៌សង្កត់ធ្ងន់ទៅលើបុគ្គលបីពួកដូចពោលមកហើយ គឺពួកបញ្ញវ័ន្ត ឥស្សរជន និងអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឲ្យពួកអ្នកទាំងនោះមានធម៌ ទើបធ្វើឲ្យសង្គមបានសេចក្តីសុខចំរើន ។ ក្រៅពីនោះ ម្តាយឪពុកនិងកូន ស្វាមីនិងភរិយា ចៅហ្វាយនិងកម្មករ គ្រូនិងសិស្សជាដើម ត្រូវមានធម៌រៀងៗខ្លួន គឺត្រូវគោរពមុខងារនាទីរបស់ខ្លួន សង្គ្រោះគ្នាទៅវិញទៅមកដោយព្រះធម៌ដែលព្រះអង្គសំដែងហើយ ។ ព្រះអង្គដាក់ព្រះធម៌ឲ្យគោរពរៀងៗខ្លួន ដើម្បីកុំឲ្យមានការជិះជាន់គ្នាក្នុងសង្គម ។ ដូច្នេះព្រះពុទ្ធជាសង្គមវិទូ សំដែងព្រះធម៌ដើម្បីឲ្យសង្គមអនុវត្ត ។ ព្រះអង្គពុំធ្វើនយោបាយដូចជាគ្រហស្ថទេ ប៉ុន្តែជាគ្រូទូន្មានអ្នកនយោបាយ ។៚